ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខ:...៤៥.វប.សវ

រាជធានីភ្នំពេញ, ថ្ងៃទី១៣.ខែ.សីហាឆ្នាំ ២០១៤

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការទទួលខុសត្រូវរួម និងគណៈកម្មការស្រាវជ្រាវ និងរៀបចំឯកសារបន្ថែម ដើម្បីស្នើសុំបញ្ចូលតាប៉ីដងវែងជាថ្មី ក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ

* * * * * * * * * *

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមការចាំបាច់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ ១.**

បង្កើតគណៈកម្មការទទួលខុសត្រូវរួមដើម្បីត្រួតពិនិត្យលើឯកសារស្នើសុំបញ្ចូលតាប៉ីដងវែងក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបី នៃមនុស្សជាតិ ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម សំរាំង កំសាន្ត | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម អ៊ុន ទឹម | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម ហាប់ ទូច | អគ្គនាយកបច្ចេកទេសវប្បធម៌ | សមាជិកអចិន្ត្រៃយ៍ |
| ៤. ឯកឧត្តម ឡុង ប៉ុណ្ណាស៊ីរីវុត្ថ | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៥. ឯកឧត្តម បុង សុវត្ថិ | សាកលវិទ្យាធិការ | សមាជិក |

| | | |
|---|---|---|
| ៦. ឯកឧត្តម ប្រាក់ សុណ្ណារ៉ា | អគ្គនាយកបេតិកភណ្ឌ | សមាជិក |
| ៧. ឯកឧត្តម សំអាង សំ | ទីប្រឹក្សាអមក្រសួង | សមាជិក |
| ៨. លោក គង់ វីរៈ | ប្រធាននាយកដ្ឋានសារមន្ទីរ | សមាជិក |
| ៩. លោក ស៊ីយ៉ុន សុភារិទ្ធិ | ជំនួយការអគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |

គណៈកម្មការនេះមានភារកិច្ចដូចតទៅៈ

- ពិនិត្យលើឯកសារ និងអត្ថបទសិក្សាស្រាវជ្រាវដែលបានចងក្រងដោយក្រុមស្រាវជ្រាវ
- កែសម្រួលខ្លឹមសារ និងរៀបចំទៅតាមទម្រង់ស្តង់ដារដែលកំណត់ដោយយូណេស្កូ
- ប្រជុំសម្រេចលើអត្ថន័យ និងខ្លឹមសារផ្សេងៗមុនពេលបញ្ជូនឯកសារទៅយូណេស្កូ

**ប្រការ ២.**

បង្កើតក្រុមការងារស្រាវជ្រាវ និងរៀបចំឯកសារបន្ថែមដើម្បីស្នើសុំបញ្ចូល ចាប៉ីដងវែង ក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបី នៃមនុស្សជាតិ ដែលមានសមាសភាព ដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. ឯកឧត្តម ហាប់ ទូច | អគ្គនាយកបច្ចេកទេសវប្បធម៌ | ប្រធាន |
| ២. ឯកឧត្តម សំអាង សំ | ទីប្រឹក្សាអមក្រសួង | អនុប្រធាន |
| ៣. ឯកឧត្តម ព្រឿង ឈាង | ទីប្រឹក្សាអមក្រសួង | សមាជិក |
| ៤. ឯកឧត្តម ហ៊ុន សារិន | ទីប្រឹក្សាអមក្រសួង | សមាជិក |
| ៥. លោក យស់ ខៀន | អគ្គនាយករងបច្ចេកទេសវប្បធម៌ | សមាជិក |
| ៦.លោក ផេង ស៊ីថា | សាកលវិទ្យាធិការរង | សមាជិក |
| ៧. លោក ឯក ប៊ុនថា | អគ្គនាយករងបច្ចេកទេសវប្បធម៌ | សមាជិក |
| ៨. លោកស្រី ហ៊ុល គឿនណារី | អគ្គនាយករងបច្ចេកទេសវប្បធម៌ | សមាជិក |
| ៩. លោក រិន ឡែដូ | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១០. លោក ម៉ៅ កេង | ប្រធាននាយកដ្ឋាន | សមាជិក |
| ១១. លោក ប៊ុក សាក់ន់ | ទីប្រឹក្សាអមក្រសួង | សមាជិក |
| ១២. លោក ង៉ូន សំអាត | ទីប្រឹក្សាអមក្រសួង | សមាជិក |
| ១៣. លោកស្រី សៀង វៀង | នាយកសាលាវិចិត្រសិល្បៈ | សមាជិក |
| ១៤. លោកស្រី ហ៊ុន ប៉ែន | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៥. លោក តន់ សុវណ្ណឧត្តម | មន្ត្រី | សមាជិក |
| ១៦. លោក ព្រាប ចាន់ម៉ារ៉ា | មន្ត្រី | សមាជិក |
| ១៧. ប្រធានមន្ទីរវប្បធម៌ និងវិចិត្រ រាជធានីខេត្ត | | សមាជិក |

គណៈកម្មការនេះមានភារកិច្ចដូចតទៅៈ

- សម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការ សមាគមន៍ ជាដៃគូ
- ចាត់ចែងចុះសិក្សាស្រាវជ្រាវប្រមូលទិន្នន័យបន្ថែម និងរៀបចំចងក្រងឯកសារ
- រៀបចំគម្រោងផែនការ និងថវិកា ដើម្បីកំណត់កម្មវិធីចុះស្រាវជ្រាវជាមួយអ្នកជំនាញពាក់ព័ន្ធក្នុងការបំពេញលក្ខខ័ណ្ឌតាមការតម្រូវរបស់គណៈកម្មការត្រួតពិនិត្យឯកសារនៃអង្គការយូណេស្កូ។
- គណៈកម្មការនេះអាចសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទដើម្បីចុះស្រាវជ្រាវប្រមូលទិន្នន័យ និង អាចអញ្ជើញមន្ត្រីជំនាញពាក់ព័ន្ធឲ្យចូលរួមប្រជុំ ពិគ្រោះយោបល់តាមការចាំបាច់។
- រាល់ឯកសារ និងខ្លឹមសារនៃអត្ថបទដែលចងក្រងឡើងដោយក្រុមការងារស្រាវជ្រាវ និងរៀបចំឯកសារបន្ថែមត្រូវឆ្លងយោបល់សម្រេចពីគណៈកម្មការទទួលខុសត្រូវរួម ។

**ប្រការ ៣.**

នាយកខុទ្ទកាល័យ អធិការនៃអធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ អគ្គនាយកបេតិកភណ្ឌ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ និងសាមីខ្លួនមានភារកិច្ច អនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រី**

ភឿង - សកុណា

**ចម្លងជូន**
- សាមីខ្លួន «ដើម្បីអនុវត្ត»
- ឯកសារ- កាលប្បវត្តិ